# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

----------

## ក្រុមហ៊ុន កាឡាខេម អ៊ិនវេសមេន ខូអិលធីឌី
## កិច្ចព្រមព្រៀង
### រវាង

តំណាងរោងចក្រ ភាគី"ក" ជាមួយ ភាគី"ខ" តំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន

ឆ្នាំពីរពាន់ម្ភៃ (២០២០) ខែ មេសា ថ្ងៃទី ២៥ វេលាម៉ោង១១ និង ០០នាទីថ្ងៃត្រង់នៅការិយាល័យ រោងចក្រ **កាឡាខេម អ៊ិនវេសមេន ខូអិលធីឌី** មានកិច្ចប្រជុំពិភាក្សា រវាងតំណាងក្រុមហ៊ុន ភាគី"ក" ជាមួយ ភាគី"ខ" តំណាងប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំរោងចក្រ។ ក្រោយពីបានប្រជុំពិភាក្សា ភាគីទាំងពីរបានយល់ព្រមព្រៀងគ្នាដូចខាងក្រោម:

១- ភាគីទាំងពីរយល់ព្រមព្យួរការងាររយៈពេល **១ខែ** ចំពោះកម្មករនិយោជិតមួយចំនួន **១៧៧ នាក់** មានផ្នែកដេរ ផ្នែកវេចខ្ចប់ ផ្នែកពិនិត្យគុណភាព ផ្នែកជាងម៉ាស៊ីន ផ្នែកឃ្លាំង និងបុគ្គលិកការិយាល័យ ដោយគិតចាប់ពី **ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០** រហូតដល់ **ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០** ដោយសារអ្នកបញ្ជាទិញផ្អាកការបញ្ជាទិញព្រោះប្រទេសទាំងនោះរងផលប៉ះពាល់ពីជម្ងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ ខូវិដ១៩ (COVID-19)។

២- ភាគី "ខ" យល់ព្រមទទួល ប្រាក់ឧបត្ថម្ភ ៣០ដុល្លារអាមេរិក ពី ភាគី"ក" និង ៤០ ដុល្លារអាមេរិក ដែលជាប្រាក់ឧបត្ថម្ភពិសេសរបស់រាជរដ្ឋាភិបាល ស្របទៅតាម "សេចក្តីណែនាំរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ៖ **០៤៥/២០ ក.ប/ស.ណ.ន.ខ.ល** ស្តីពី ការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប.ស.ស. សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវិត-១៩" ដូច្នេះជាសរុបកម្មករនិយោជិតម្នាក់ៗទទួលបាន **៧០ដុល្លារអាមេរិក ក្នុង ១ខែ** សំរាប់រយៈពេលព្យួរការងារនេះ។

៣- ភាគី"ក" នឹងបើក **៣០ ដុល្លារអាមេរិក** នេះជូន ភាគី"ខ" នៅថ្ងៃទី១០ នៃខែបន្ទាប់ (តែ១លើកប៉ុណ្ណោះ)។

៤- ភាគី"ខ" ត្រូវត្រលប់ចូលមកធ្វើការវិញនៅថ្ងៃទី **០១ ខែ មិថុនា ឆ្នាំ ២០២០** ក្នុងករណីបងប្អូន កម្មករមិនបានចូលធ្វើការតាមការកំណត់នេះទេ រោងចក្រនឹងអនុវត្តន៍តាមបទបញ្ជាផ្ទៃក្នុង និងច្បាប់ស្តីពីការងារ ។

កិច្ចព្រមព្រៀងនេះ ចាប់អនុវត្តន៍និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសៅរ៍ ០៤ កើត ខែ ពិសាខ ឆ្នាំជូត ទោស័ក២៥៦៣

កំពង់ស្ពឺ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០២០

ស្នាមមេដៃតំណាងប្រតិភូបុគ្គលិកកម្មករ និងប្រធានក្រុម

១- ឈ្មោះ ......**ខិន ស្រីមុំ**...... តួនាទី **ប្រធានក្រុម** ហត្ថលេខា ..............

២- ឈ្មោះ ......**ជួប សុគន់**...... តួនាទី ......**ប្រតិភូ**...... ហត្ថលេខា ..............

៣- ឈ្មោះ ......**សួ សារី**...... តួនាទី **ប្រធានក្រុម** ហត្ថលេខា ..............

៤- ឈ្មោះ ......**ស៊ុយ អន**...... តួនាទី ......**ប្រតិភូ**...... ហត្ថលេខា ..............

៥- ឈ្មោះ ......**អាំង ហៀង**...... តួនាទី **ប្រធានក្រុម** ហត្ថលេខា ..............

៦- ឈ្មោះ ......**ទូច សុខខេ**...... តួនាទី ......**ប្រតិភូ**...... ហត្ថលេខា ..............

**តំណាងក្រុមហ៊ុន**

CALACAM INVESTMENT CO.,LTD.

**ឆេង ណារ៉ុង**

**តួនាទី: រដ្ឋបាល**